រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលក្រុងព្រះសីហនុ ប្រធានសភាពាណិជ្ជកម្មក្រុងព្រះសីហនុ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និង មាត្រា ២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខៈ ១០៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្ម

ខេត្តកំពង់ចាម អាណត្តិទី ១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តកំពង់ចាម
- ផ្អែកតាមកំណត់ហេតុ ស្តីពីការបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មខេត្តកំពង់ចាម អាណត្តិទី ១ ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៥ របស់គណៈកម្មការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម ខេត្តកំពង់ចាម
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

មាត្រា ១.-

ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តកំពង់ចាម ចំនួន ១៥រូប ដូចខាងក្រោម :

១-	អ្នកស្រី	ទ៊ា	ណារីន
២-	លោកបណ្ឌិត	ជួន	ទុន្សី
៣-	កញ្ញា	អឿង	សោភ័ណ្ឌ
៤-	លោក	យ៉ាន	គង់
៥-	ឧកញ៉ា	ឈន	ថាវី
៦-	ឧកញ៉ា	អាន	ម៉ាឌី
៧-	លោក	យ៉ើន	សារិទ្ធ
៨-	លោក	ឆែ	ឌឿន
៩-	លោក	ឈុន	ភុសល
១០-	លោក	ភុយ	សុខចន់
១១-	លោក	ហួត	ឈឿន
១២-	លោក	ហេង	ឡុង
១៣-	ឯកឧត្តម	សុខ	ហ៊ាង
១៤-	លោក	គឹម	ម៉េងហួត
១៥-	លោក	ផេន	សុផល

មាត្រា ២ .-

ទទួលស្គាល់ឧកញ៉ា **អាន ម៉ាឌី** ជាប្រធានសភាពាណិជ្ជកម្មខេត្តកំពង់ចាម ។

មាត្រា ៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកំពង់ចាម ប្រធានសភាពាណិជ្ជកម្មខេត្តកំពង់ចាម និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និង មាត្រា ២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៩៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការទទួលស្គាល់សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្ម
ខេត្តសៀមរាប អាណត្តិទី ១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបបនិងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្ម ខេត្តសៀមរាប
- ផ្អែកតាមកំណត់ហេតុ ស្តីពីការបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្ម ខេត្តសៀមរាប អាណត្តិទី ១ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ ២០០៤ របស់គណៈកម្មការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម ខេត្តសៀមរាប
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

មាត្រា ១.-

ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម ខេត្តសៀមរាប ចំនួន ១៥រូប ដូចខាងក្រោម :

១-លោក ផេង គង់
២-លោក ឡុង សារ៉ិន
៣-លោក សោម ចណ្ណា
៤-លោក ទ៊ាន់ សារឿន
៥-ឧកញ៉ា ភាំង អៀងឈី
៦-លោក ហ៊ុន មុន្នីចណ្ណ
៧-លោក តាន់ ម៉ុនចេង
៨-លោក ធី សុគន្ធា
៩-លោក ប៉ិល ហួឈី
១០-លោក សេន រី
១១-លោក ម៉ឿង សុន
១២-លោក រស់ ហៃ
១៣-លោក ម៉ុន ម៉េង
១៤-លោក ឈាវ គង់
១៥-លោក ម៉ុន ហៃ

មាត្រា ២ .-

ទទួលស្គាល់លោក **ផេង គង់** ជាប្រធានសភាពាណិជ្ជកម្ម ខេត្តសៀមរាប ។

មាត្រា ៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តសៀមរាប ប្រធានសភាពាណិជ្ជកម្មខេត្តសៀមរាប និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ [illegible] អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្ម ខេត្តកំពត អាណត្តិទី ១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តកំពត
- ផ្អែកតាមកំណត់ហេតុ ស្តីពីការបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មខេត្តកំពត អាណត្តិទី ១ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៥ របស់គណៈកម្មការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម ខេត្តកំពត
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

មាត្រា ១.-

ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តកំពត ចំនួន ១៥រូប ដូចខាងក្រោម ៖

១- លោកស្រី ហូ គីម
២- លោក អ៊ុំ ឈុន
៣- លោក តាន់ ណារី
៤- លោក ស៊ុន នួន
៥- លោក ជា អ៊ីម
៦- លោកស្រី ឈុត ពៅ
៧- លោកស្រី ជុំ សុខា
៨- លោក គង់ គិច
៩- លោក ឌុន សាខន
១០- លោក ខួន សុផល
១១- លោកស្រី សំ ចរិយា
១២- លោកស្រី ថ្ងាំ សុផល
១៣- លោក ថ្កួន សុផល
១៤- លោក ចាន់ ស៊ីថា
១៥- លោកស្រី លី សៀវលៀង

មាត្រា ២ .-

ទទួលស្គាល់លោក អ៊ុំ ឈុន ជាប្រធានសភាពាណិជ្ជកម្មខេត្តកំពត ។

មាត្រា ៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកំពត ប្រធានសភាពាណិជ្ជកម្មខេត្តកំពត និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និង មាត្រា ២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ [illegible] អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការទទួលស្គាល់សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្ម ខេត្តបាត់ដំបង អាណត្តិទី ១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្ម ខេត្តបាត់ដំបង
- ផ្អែកតាមកំណត់ហេតុ ស្តីពីការរៀបចំបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្ម ខេត្តបាត់ដំបង ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៤ របស់គណៈកម្មការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម ខេត្តបាត់ដំបង
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

មាត្រា ១.-

ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម ខេត្តបាត់ដំបង ចំនួន ១៥រូប ដូចខាងក្រោម :

១-លោក ភួ ពុយ
២-លោកស្រី គឹម ហាន
៣-លោក ម៉ុន ជេត
៤-លោក សុខ ហុខ
៥-លោក ចាន់ សុខឡូ
៦-លោក អ៊ុខ គឹមឈី
៧-លោកស្រី ខិន បៀខ
៨-លោក សខ ថន
៩-លោក ចាន់ ឈាខ
១០-លោក ហេខ ឆាត
១១-លោក ទើខ ស្រ៊ុន
១២-លោក ហ៊ុន ទិបុល
១៣-លោក ហុខ ជ្រិន
១៤-លោក គីខ ចាន់ឡាយ
១៥-លោកជំទាវ ឈួន នួច

មាត្រា ២ .-

ទទួលស្គាល់លោក ភួ ពុយ ជាប្រធានសភាពាណិជ្ជកម្ម ខេត្តបាត់ដំបង ។

មាត្រា ៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តបាត់ដំបង ប្រធានសភាពាណិជ្ជកម្មខេត្តបាត់ដំបង និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និង មាត្រា ២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...១២២៦...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការទទួលស្គាល់សមាជិកជ្រើសតាំងនៃសភាពាណិជ្ជកម្ម ខេត្តបន្ទាយមានជ័យ អាណត្តិទី ១

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្ម ខេត្តបន្ទាយមានជ័យ
- ផ្អែកតាមកំណត់ហេតុ ស្តីពីការបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្ម ខេត្តបន្ទាយមានជ័យ អាណត្តិទី១ ថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៤ របស់គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើសសមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម ខេត្តបន្ទាយមានជ័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

មាត្រា ១.-

ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម ខេត្តបន្ទាយមានជ័យ ចំនួន ១៥រូប ដូចខាងក្រោម :

១-លោកស្រី ចក់ ពួក
២-លោក គិន យ៉ុន
៣-លោក និត្យ លេក
៤-លោក យឿម គង់
៥-ឧកញ៉ា អ៊ុំ ឆាយ
៦-លោក ប៊ុន សុខ
៧-ឧកញ៉ា ហង្ស ស៊ីផា
៨-លោក សុខ ឈាង
៩-លោក ច័ន្ទ ហោង
១០-លោក ឈាង ពត
១១-លោក លឹម ម៉ី
១២-លោក លឹម ស្រេង
១៣-លោក លី អ៊ុតនី
១៤-លោក សុខ គង់
១៥-លោក តាន់ ទរ៉ា

មាត្រា ២ .-

ទទួលស្គាល់ឧកញ៉ា អ៊ុំ ឆាយ ជាប្រធានសភាពាណិជ្ជកម្ម ខេត្តបន្ទាយមានជ័យ ។

មាត្រា ៣ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តបន្ទាយមានជ័យ ប្រធានសភាពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និង មាត្រា ២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:......៣២៩......អនក្រ-បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូននាយទាហានជាន់ខ្ពស់ នៃយោធភូមិភាគទី៩ កងទ័ពប្រជាជនវៀតណាម ចំនួន ០៩រូប ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ និង ជួយឧបត្ថម្ភដល់យោធភូមិភាគទី១ នៃកងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :

-ឧត្តមសេនីយ៍ទោ HUYNH NGOC SON មេបញ្ជាការយោធភូមិភាគទី៩

ខ-មេដាយសហមេត្រី ថ្នាក់ សេនា :

១-ឧត្តមសេនីយ៍ត្រី NGUYEN VAN TIEN មេបញ្ជាការរង - នាយសេនាធិការ

២-ឧត្តមសេនីយ៍ត្រី CHINH CONG THUC មេបញ្ជាការរង យោធភូមិភាគទី៩

៣-ឧត្តមសេនីយ៍ត្រី LAC NAM DUONG មេបញ្ជាការរង យោធភូមិភាគទី៩

៤-ឧត្តមសេនីយ៍ត្រី VO TIEN TRUNG មេបញ្ជាការរង យោធភូមិភាគទី៩

៥-ឧត្តមសេនីយ៍ត្រី NGUYEN VAN THANG មេបញ្ជាការរង យោធភូមិភាគទី៩

/៦

គ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ :

១-វរសេនីយ៍ឯក NGUYEN THANH DUC ប្រធានស្នងការនយោបាយ យភក៩

២-វរសេនីយ៍ឯក DO QUANG DU ប្រធានស្នងការភស្តុភារ យភក៥

៣-វរសេនីយ៍ឯក LE THANH HAI ប្រធានស្នងការបច្ចេកទេស យភក៩

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពល ខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧២៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.–

បង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដែលហៅកាត់ថា "គ.ជ.ប.ប " ដើម្បីសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការនានាដែលពាក់ព័ន្ធ ដើម្បីអភិវឌ្ឍប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ អោយឆ្លើយតបទៅនឹង សេចក្តីត្រូវការរបស់សង្គមសេដ្ឋកិច្ចបច្ចុប្បន្ន និងទៅអនាគតនៅកម្ពុជា។

មាត្រា ២.–

- សមាសភាពនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាលមានដូចខាងក្រោម :

១. ឯកឧត្តម **សុខ អាន**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	ប្រធាន
២. ឯកឧត្តម **ពេជ សោភ័ន**	រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អនុប្រធាន
៣. ឯកឧត្តម **សយ ស៊ីផុន**	រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	អនុប្រធាន
៤. ឯកឧត្តម **ម៉ក់ វ៉ាន់**	រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា	អនុប្រធាន
៥. លោក **វ៉ាន់ ស៊ុនអៀង**	ប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា	អនុប្រធាន
៦. ឯកឧត្តម **ឡា ណារ៉ាត**	រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក

៧. ឯកឧត្តម **សំ ព្រហ្មនា** រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ សមាជិក

៨. ឯកឧត្តម **ម៉ែន ឃាន** រដ្ឋលេខាធិការ ក្រសួងផែនការ សមាជិក

៩.ឯកឧត្តម **ម៉ា ជាង** អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម សមាជិក

១០.ឯកឧត្តម **នូ មុត** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១១.ឯកឧត្តម **ស្លួត សំបូរ** អគ្គនាយករដ្ឋបាល ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

១២. ឯកឧត្តម **ជួប សំអាត** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

១៣. លោកជំទាវ **ជូ ប៊ុនអេង** អគ្គនាយកអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី សមាជិក

១៤. ឯកឧត្តម **លាភ វណ្ណះដេន** អគ្គលេខាធិការរង គណៈកម្មាធិការនីតិសម្បទា និងការអភិវឌ្ឍន៍ / ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១៥. ឯកឧត្តមបណ្ឌិត **អ៊ុំ សុផល** សកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ក្រសួងសុខាភិបាល សមាជិក

១៦. បណ្ឌិត **ហ៊ាន សាហ៊ីប** អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៧. លោក **ត្រាំ សំអ៊ាន** អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១៨. លោក **អ៊ិច បូរ៉ា** អគ្គនាយករងនៃអគ្គនាយកដ្ឋានធនធានរ៉ែ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

១៩. លោក **សំ ខាន់ឌី** អគ្គនាយករងបច្ចេកទេស ក្រសួងបរិស្ថាន សមាជិក

២០. លោកឧកញ៉ា **ណាង សុធី** អគ្គនាយក សភាពាណិជ្ជកម្មកម្ពុជា សមាជិក

២១.លោក **តាន់ មុនីវណ្ណ** អគ្គនាយករង ក្រុមហ៊ុន ម៉ុង ឫទ្ធីគ្រុប ជាតំណាងនិយោជក សមាជិក

២២. លោក **ខេង លូ** តំណាងវិស័យឧស្សាហកម្មកាត់ដេរ ជាតំណាងនិយោជក សមាជិក

២៣. លោក **សុខ ខេង** តំណាងវិស័យឧស្សាហកម្មសណ្ឋាគារ ជាតំណាងនិយោជក សមាជិក

២៤ លោក **ជួន មុំ ថុល** ប្រធានសហភាពសហព័ន្ធសហជីពជាតិកម្ពុជា ជាតំណាងនិយោជិត សមាជិក

២៥. លោក **វស់ សុភ** អនុប្រធានទី ១ សហភាពសហព័ន្ធសហជីពជាតិកម្ពុជា ជាតំណាងនិយោជិត សមាជិក

២៦. ឯកឧត្តម **ប៊ុន តារិន** នាយកវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា តំណាងអ្នកផ្តល់ការបណ្តុះបណ្តាល សមាជិក

២៧. លោក **ជុន ណារ៉ាវី** គ្រូបង្រៀន និងជំនួយការនាយក តំណាងអ្នកផ្តល់ការបណ្តុះបណ្តាល សមាជិក

២៨. លោកស្រី **ដួង ច័ន្ទដេត** នាយិកាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង តំណាងអ្នកផ្តល់ការបណ្តុះបណ្តាល សមាជិក

២៩.ឯកឧត្តម **ឡៅ ហ៊ឹម** អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាយកប្រតិបត្តិ

- គណៈកម្មាធិការជាតិអាចអញ្ជើញតំណាង ៣រូប របស់អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ចូលរួមបាន។
- គណៈកម្មាធិការជាតិនេះមាន អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍ ។

មាត្រា ៣.-

គណៈកម្មាធិការជាតិនេះមានភារកិច្ច :

- រៀបចំគោលនយោបាយ និងគំរោងផែនការជាតិ សំរាប់អប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ។
- សម្របសម្រួល និងតំរង់ទិសការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីឆ្លើយតបទៅនឹងតំរូវការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ។
- លើកគំរោងកែទំរង់ និងអភិវឌ្ឍ ប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីអោយក្លាយជាប្រព័ន្ធមួយដែល :
    - មានគុណភាព និងប្រសិទ្ធភាពខ្ពស់
    - ផ្សារភ្ជាប់ទៅនឹងអាទិភាពនៃការអភិវឌ្ឍន៍ជាតិ
    - ឆ្លើយតបទៅនឹងតម្រូវការរបស់ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម សេវាកម្ម ។ល។
    - មានទំនាក់ទំនងរវាងកន្លែងធ្វើការងារ និងគ្រឹះស្ថានបណ្តុះបណ្តាល

មាត្រា ៤.-

- គណៈកម្មាធិការជាតិ ត្រូវជ្រើសតាំងសមាជិករបស់ខ្លួន ៥រូប ធ្វើជាគណៈកម្មការប្រតិបត្តិ ដែលមានសមាសភាព ដូចខាងក្រោម :

- ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	ប្រធាន
- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អនុប្រធាន
- តំណាង ២រូប របស់ក្រសួង ឬ ស្ថាប័នរាជរដ្ឋាភិបាល	សមាជិក
- តំណាង ២រូប របស់និយោជក	-
- តំណាង ១រូប របស់និយោជិត	-
- តំណាង ១រូប របស់អ្នកផ្តល់ការបណ្តុះបណ្តាល	-

- គណៈកម្មការប្រតិបត្តិអាចអញ្ជើញតំណាង ១រូប របស់អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលចូលរួម ។
- គណៈកម្មការប្រតិបត្តិនេះមាននាយកប្រតិបត្តិធ្វើជាលេខាធិការ ។

មាត្រា ៥.-

គណៈកម្មការប្រតិបត្តិនេះមានភារកិច្ច :

- គ្រប់គ្រងក្នុងនាមគណៈកម្មាធិការជាតិ នូវមូលនិធិជាតិបណ្តុះបណ្តាល ។
- រៀបចំកម្មវិធី និងរបៀបវារៈប្រជុំ របស់គណៈកម្មាធិការជាតិ ។
- លើកសំណើដែលពាក់ព័ន្ធដល់ការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជូនគណៈកម្មាធិការជាតិ ពិនិត្យ និងសំរេច ។

មាត្រា ៦.-

នៅតាមខេត្ត-ក្រុង ត្រូវបង្កើតអោយមានគណៈកម្មាធិការសម្របសម្រួលការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

ថ្នាក់ខេត្ត-ក្រុង ដែលហៅកាត់ថា គណៈកម្មាធិការខេត្ត-ក្រុងបណ្តុះបណ្តាល ។ សមាសភាពគណៈកម្មាធិការនេះរួមមាន : អភិបាលខេត្ត-ក្រុង ជាប្រធាន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាអនុប្រធាន ប្រធានមន្ទីរពាក់ព័ន្ធ តំណាងអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល តំណាងនិយោជក តំណាងនិយោជិត និងតំណាងអ្នកផ្តល់ការបណ្តុះបណ្តាល ជាសមាជិក ហើយមានការិយាល័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត-ក្រុង ជាលេខាធិការដ្ឋាន ។

មាត្រា ៧.-

ភារកិច្ចរបស់គណៈកម្មាធិការខេត្ត-ក្រុងបណ្តុះបណ្តាល ត្រូវកំណត់ក្នុងលក្ខន្តិកៈដោយគណៈកម្មាធិការជាតិបណ្តុះបណ្តាល ។

មាត្រា ៨.-

គណៈកម្មាធិការជាតិបណ្តុះបណ្តាលមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១០.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុង គណៈកម្មាធិការជាតិបណ្តុះបណ្តាល និងបណ្តាសមាសភាពដូចមានចែងក្នុងមាត្រា ២ មាត្រា ៤ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

អគ្គលេខាធិការរាជរដ្ឋាភិបាល

ដូចមាត្រា ២ -មាត្រា ៤ -មាត្រា ១០

ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤១ សសរ

សេចក្តីសំរេច

ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥ រហូតដល់សម្តេច នាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០៥

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-*ក្រសួងព្រះបរមរាជវាំង*

-*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

-*អគ្គលេខាធិការដ្ឋានរដ្ឋសភា*

-*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

-*ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

-*ដូចប្រការ ២*

-*ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៧៣៩ ឧរថ.កឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ០០៣ អគវ.កច ចុះថ្ងៃទី២៨.០៦.២០០៥ របស់អនុគណៈកម្មាធិការវិនិយោគខេត្តកំពង់ចាម
- យោងលិខិតលេខ ២៣៣ ឧរថ.កច ចុះថ្ងៃទី១១.០៨.២០០៥ របស់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្តកំពង់ចាម
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ស៊ាង ហ្វុង ឌីវេឡុបមេន អេគ្រីខលឈ័រ ចុះថ្ងៃទី០៨.០៦.២០០៥

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ាង ហ្វុង ឌីវេឡុបមេន អេគ្រីខលឈ័រ (SIANG PHONG DEVELOPMENT AGRICULTURE CO., LTD.) តំណាងដោយលោកស្រី អ៊ូ មន្ថា សញ្ជាតិខ្មែរ អាយុ៦៦ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ 060010686 ចុះថ្ងៃទី២៦.០៧.២០០០ បង្កើតរោងចក្រ "កែច្នៃម្សៅដំឡូងមី"ដែលមានឈ្មោះថា "ស៊ាង ហ្វុង ឌីវេឡុបមេន អេគ្រីខលឈ័រ (SIANG PHONG DEVELOPMENT AGRICULTURE)" មានទីតាំងស្ថិតនៅ ភូមិឡ ឃុំកោងកាង ស្រុកពញាក្រែក ខេត្តកំពង់ចាម ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុន ត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កែច្នៃម្សៅជ័រឡុងមី" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្ម របស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខ រោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពង់ចាម និងប្រធានក្រុមហ៊ុន ស៊ាង ហ្វុង ឌីវើឡុបមេន អេហ្គ្រីខលឈើរ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- អនុគណៈកម្មាធិការវិនិយោគខេត្តកំពង់ចាម
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៩ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៧៤០ ឧស្ម.ករ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២៨៤៧/០៥ គ.វ.ក ចុះថ្ងៃទី១៧.០៨.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អ៊ិនធើ ហូភីវែល ហ្គាមេន ចុះថ្ងៃទី៣០.០៦.២០០៥

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អ៊ិនធើ ហូភីវែល ហ្គាមេន (INTER HOPEWELL GARMENT CO., LTD.) តំណាងដោយ លោកស្រី ខូវ លីគាង សញ្ជាតិខ្មែរ អាយុ៤២ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៣៥១៤៣២ ចុះថ្ងៃទី ០៨.០៤.២០០២ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "អ៊ិនធើ ហូភីវែល ហ្គាមេន (INTER HOPEWELL GARMENT)" មានទីតាំងស្ថិតនៅអតីតរោងចក្រ BEST HONOUR INTERNATIONAL GARMENT ផ្លូវជាតិលេខ៣ ភូមិកប់គង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

<u>ប្រការ២</u>: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុន ត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៣</u>: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៤</u>: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយៈមើលឃើញនៅខាងមុខ រោងចក្រ ។

<u>ប្រការ៥</u>: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

<u>ប្រការ៦</u>: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

<u>ប្រការ៧</u>: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

<u>ប្រការ៨</u>: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

<u>ប្រការ៩</u>: ប្រកាសលេខ ៤៩៧ ឧក.ប្រក ចុះថ្ងៃទី២៤.០៨.១៩៩៨ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់របស់ក្រុមហ៊ុន (BEST HONOUR INTERNATIONAL GARMENT CO., LTD.) ត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ១០</u>: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អ៊ិនចើ ហូភីវែល ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

<u>ប្រការ១១</u>: ប្រកាសនេះមានអនុភាពគតិយុត្តិ រាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

<u>ចម្លងជូន</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប"

- ដូចប្រការ ១០ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N°៧៧១ ឧ៥ម.ករ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣១៧៧/០៥ ត.វ.ក ចុះថ្ងៃទី១៥.០៩.២០០៥ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន វ៉ាយថិច ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី២២.០៩.២០០៥

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាយថិច ហ្គាមេន (ខេមបូឌា)(WHITEX GARMENTS (CAMBODIA) CO., LTD.) តំណាងដោយ លោកស្រី LEE LI HEONG សញ្ជាតិម៉ាឡេស៊ី អាយុ៤៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ A10646501 ចុះថ្ងៃទី០២.០៨.២០០១ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " វ៉ាយថិច ហ្គាមេន (ខេមបូឌា) (WHITEX GARMENTS (CAMBODIA))" មានទីតាំងស្ថិតនៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ . ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែអំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន វ៉ាយថិច ហ្គាមេន (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ៧៧៣ ឧរម.ឧគស.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

ប្រកាស
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព និងសុវត្ថិភាពលើផលិតផល ទំនិញ និងសេវា
- បានឃើញសារាចរលេខ ០៣ សរ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រងគុណភាព និងវិធានការណ៍ត្រួតពិនិត្យគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងចំណីអាហារ ដែលមានប្រើសារជាតិគីមី
- យោងស្មារតីអង្គប្រជុំផ្ទៃក្នុងអគ្គនាយកដ្ឋានឧស្សាហកម្ម ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៥
- ការងារចាំបាច់ និងបន្ទាន់របស់ក្រសួង ។

សំរេច

ប្រការ១: បង្កើតក្រុមការងារមួយដែលមានឈ្មោះថាក្រុមការងារជំរុញបង្កើនគុណភាពផលិតផល មានសមាសភាពដូចខាងក្រោម:

១-	លោក	សាត សមុទ្រ	អគ្គនាយករងឧស្សាហកម្ម	ប្រធាន
២-	លោកស្រី	ឡាយ ណាទីន	អនុប្រធាននាយកដ្ឋានឧស្សាហកម្មតូច និងសិប្បកម្ម	អនុប្រធាន
៣-	លោក	យ៉ា ម៉ុនណា	អនុប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម	សមាជិក
៤-	លោក	ទាន់ សុផា	អនុប្រធាននាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា	-
៥-	លោក	អ៊ុន សំបូរ	ប្រធានមន្ទីរពិសោធន៍មីក្រូជីវសាស្ត្រចំណីអាហារ និងគីមីសាស្ត្រ	-
៦-	លោក	ជាវ ចាន់នី	អនុប្រធានការិយាល័យ នាយកដ្ឋានទឹកស្អាត	-
៧-	លោក	ម៉ឹយ បុណ្ណរាត	មន្ត្រីនាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម	-
៨-	លោក	ជ័យ បញ្ញារត្ន័	មន្ត្រីនាយកដ្ឋានឧស្សាហកម្មតូច-សិប្បកម្ម	-
៩-	លោក	ឡុង អាល់ភាលីន	មន្ត្រីមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា	-
១០-			មន្ត្រីមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត-ក្រុង	-

ដើម្បីចុះតាមមូលដ្ឋានឧស្សាហកម្ម-សិប្បកម្ម ជាពិសេសមូលដ្ឋានផលិតម្ហូបអាហារ ភេសជ្ជៈ ដែលកំពុងតែប្រតិបត្តិការក្នុងខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការអនុវត្តន៍អោយបានត្រឹមត្រូវតាមស្តង់ដា និងគុណភាពកំណត់ ។/.

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២:- ក្រុមការងារត្រូវពិនិត្យសកម្មភាពផលិតកម្មជំរុញបង្កើនគុណភាពផលិតផល ព្រមទាំងជ្រើសរើសគំរូផលិតផលដែលមានការសង្ស័យ ដើម្បីវិភាគគុណភាពនៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា ។ ក្នុងករណីពិនិត្យឃើញថា ផលិតផលណាដែលមិនត្រឹមត្រូវតាមស្តង់ដា និង គុណភាពកំណត់ ដែលធ្វើអោយប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ក្រុមការងារត្រូវធ្វើការណែនាំអនុវត្តអោយបានត្រឹមត្រូវ ឬផ្អាកជាបណ្តោះអាសន្នក្នុងករណីធ្ងន់ធ្ងររួចធ្វើសេចក្តីរាយការណ៍ជូនថ្នាក់ដឹកនាំដើម្បី សុំការណែនាំ ។ ក្នុងករណីចាំបាច់ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចុះពិនិត្យសកម្មភាពផលិតកម្មនៃឧស្សាហកម្ម-សិប្បកម្ម ។

ប្រការ៣:- ក្រុមការងារត្រូវ:

- ផ្តល់យោបល់ ឬណែនាំលើការងារបច្ចេកទេស ការងារផលិតភាព និងការងាររបាយការណ៍
- លើកទឹកចិត្តតាមរយៈនៃការបញ្ជូនទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗ ក្នុង និងក្រៅប្រទេស
- ទទួលសំណូមពររបស់ឧស្សាហករ-សិប្បករជូនថ្នាក់ដឹកនាំក្រសួង ដើម្បីមានវិធានការណ៍ដោះស្រាយ ។

ប្រការ៤:- ក្រុមការងារត្រូវអនុវត្តជាប្រចាំតាមកម្មវិធីច្បាស់លាស់របស់ខ្លួន ឬជាបន្ទាន់ក្នុងករណីមានបាតុភាពកើតឡើង ធ្វើអោយប៉ះពាល់សុវត្ថិភាពដល់អ្នកប្រើប្រាស់ ។

ប្រការ៥:- ប្រធានក្រុមការងារត្រូវធ្វើរបាយការណ៍អំពីលទ្ធផលជូនថ្នាក់ដឹកនាំក្រសួងជារៀងរាល់ខែ ។

ប្រការ៦:- អគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលគ្រប់ខេត្ត-ក្រុង និងសាមីជន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តលិខិតបង្គាប់ការនេះតាមមុខការរៀងៗ ខ្លួន ។

ប្រការ៧:- ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ សែម

ចំលងជូន:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ
- ក្រសួងមហាផ្ទៃ
- សាលាខេត្ត-ក្រុង

 "ដើម្បីជ្រាប"

- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខ: ៦៧២១. សរណប.ស្ថ.កអធ

រាជធានីភ្នំពេញ. ថ្ងៃទី...១៤...ខែ...តុលា...ឆ្នាំ២០០៥

សេចក្តីណែនាំ

ស្តីពីការទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការលោះបង្គោលរបងចាប់យកដី ការកាប់ឆ្ការរុករានទន្ទ្រានយកដីព្រៃ ដុតព្រៃធម្មជាតិធ្វើចំការដាំដុះ ឈូសឆាយដីព្រៃ យកដីធ្វើជាកម្មសិទ្ធិនៅក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" ក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ

ក្រសួងបរិស្ថានបានសង្កេតឃើញថា កន្លងមកភាពអនាធិបតេយ្យក្នុងការកាប់ឆ្ការរុករានទន្ទ្រានដីព្រៃ ការបោះបង្គោលរបងចាប់យកដី និងការដុតព្រៃធម្មជាតិធ្វើការដាំដុះ កាប់គាស់ ជីកកកាយយកដី ឈូសឆាយដីព្រៃ ឬធ្វើផ្លូវ និងសាងសង់សំណង់គ្រប់ប្រភេទ ព្រមទាំងធ្វើសកម្មភាពនានាខុសច្បាប់ផ្សេងទៀត ដែលធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិនៅក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" ជាពិសេសនៅតាមតំបន់ព្រៃកទឹកសាប តំបន់ជាប់ព្រំប្រទល់កងនាវាចរមូលដ្ឋានសមុទ្ររាម និងតំបន់ឆ្នេរសមុទ្ររាម ស្ថិតនៅក្នុងភូមិសាស្ត្រខណ្ឌព្រៃនប់ ក្រុងព្រះសីហនុបានកើតឡើងជាបន្តបន្ទាប់ ដោយគ្មានក្រែងរអែងដល់ការអនុវត្តន៍ច្បាប់ឡើយ។

អនុវត្តតាមបទបញ្ជា និងគោលការណ៍ណែនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រីក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ពិសេសការអនុវត្តន៍ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានាដែលនៅជាធរមាន រួមមាន:

- ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ។
- ព្រះរាជក្រមលេខ នស/រកម/១២៩៦.៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។
- ព្រះរាជក្រមលេខនស/រកម/០៨០១.១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល។
- ព្រះរាជក្រមលេខ នស/រកម/០៨០២.០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ។
- សេចក្តីប្រកាសលេខ ០១ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ។

- សេចក្ដីប្រកាសលេខ ០៦ ប្រក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាល ស្ដីពីវិធានការលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្ទ្រានកាន់កាប់ដីធ្លី។
- បទបញ្ជាលេខ ០១បប ចុះថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាល ស្ដីពីការទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុត ឈូសឆាយ និងហ៊ុំព័ទ្ធដីព្រៃឈើ ដើម្បីរាតយកដីធ្វើជាកម្មសិទ្ធិនៅតាមបណ្ដាខេត្ត ក្រុងមួយចំនួន។
- លិខិតលេខ ១០៧៤ សជណ.កស ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០០៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

ក្នុងគោលដៅធ្វើការគ្រប់គ្រង ថែរក្សា ការពារធនធានធម្មជាតិ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ បានប្រកបដោយនិរន្តរភាពបរិស្ថានធម្មជាតិយូរអង្វែង សម្រាប់ជាកេរ្តិ៍ដំណែលដល់អនាគតកូនចៅ ចៅទួតជំនាន់ក្រោយ និងការពារគ្រោះធម្មជាតិដែលអាចកើតឡើងជាយថាហេតុ និងសម្រេចឱ្យបាននូវផែនការយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងអណ្ដត្តិទី៣នេះ ក្រសួងបរិស្ថានសូមធ្វើការណែនាំ និងជូនដំណឹងដល់បងប្អូន ឬជនទាំងឡាយដែលបាន និងកំពុងបោះបង្គោលរបងចាប់យកដី កាប់ឆ្ការរុករានទន្ទ្រានដីព្រៃ ដុតព្រៃធម្មជាតិធ្វើការដាំដុះ កាប់គាស់ ជីកកកាយយកដី ឈូសឆាយដីព្រៃ ឬធ្វើផ្លូវ និងសាងសង់សំណង់គ្រប់ប្រភេទ ព្រមទាំងធ្វើសកម្មភាពនានាខុសច្បាប់ផ្សេងទៀត ដែលធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិនៅក្នុងតំបន់ឧទ្យានជាតិព្រះសីហនុ "រាម" ក្នុងភូមិសាស្ត្រខ័ណ្ឌព្រៃនប់ ក្រុងព្រះសីហនុទាំងមូល ត្រូវបញ្ឈប់សកម្មភាពខាងលើទាំងអស់ជាបន្ទាន់ ព្រមទាំងត្រូវប្រគល់ដីដែលបានកាប់ឆ្ការ រុករាន ឬឈូសឆាយទាំងអស់ ហើយមានកន្លែងខ្លះបានដាំដុះរួចហើយនោះ ក៏ត្រូវប្រគល់ជូនមកឱ្យឧទ្យានជាតិព្រះសីហនុ "រាម" វិញ ដើម្បីធ្វើការគ្រប់គ្រង ការពារជាសម្បត្តិសាធារណៈរបស់រដ្ឋ។

ក្នុងករណីដែលបងប្អូន ឬជនណាដែលចចេសរឹងទទឹងមិនព្រមបញ្ឈប់នូវរាល់សកម្មភាពឈូសឆាយ រុករាន កាប់ព្រៃធម្មជាតិ ដែលធ្វើឱ្យប៉ះពាល់ និងបំផ្លិចបំផ្លាញដល់ធនធានធម្មជាតិ នៅក្នុងតំបន់ការពារធម្មជាតិខាងលើ ឬមិនអនុវត្តតាមគោលការណ៍ដូចខាងលើនេះទេ ក្រសួងបរិស្ថានសហការជាមួយអាជ្ញាធរដែនដី និងកម្លាំងសហការពាក់ព័ន្ធផ្សេងទៀត នឹងចាត់វិធានការចុះរុះរើ ព្រមទាំងរៀបចំសំណុំរឿងបទល្មើសបញ្ជូនទៅតុលាការ ដើម្បីចាត់ការទៅតាមផ្លូវច្បាប់ជាធរមាន។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ជីវវិទ្យា

កន្លែងទទួល:

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទល័យឧបនាយករដ្ឋមន្ត្រី ស ខេង
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ
- អភិបាលក្រុងព្រះសីហនុ
- មន្ទីរបរិស្ថានក្រុងព្រះសីហនុ
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខៈ ១១០១ អយក.ប្រក

ប្រកាស

ស្តីពីការពង្រីកអនុវិទ្យាល័យ " ហ៊ុន សែន ពោធិ៍អំពិល " ទៅជាវិទ្យាល័យ " ហ៊ុន សែន ពោធិ៍អំពិល " ស្ថិតនៅក្នុង ឃុំ សំបូរ ស្រុក ទ្រាំង ខេត្ត តាកែវ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ១២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកម្រិត១- កម្រិត២
- យោងពាក្យស្នើសុំរបស់សហគមន៍ ឃុំ សំបូរ ស្រុក ទ្រាំង ចុះថ្ងៃទី ២៧ មិថុនា ២០០៥ ដោយមានដោយមានយោបល់ឯកភាពពី មន្ទីរ អប់រំ យុវជន និង កីឡា និងលោកអភិបាលខេត្ត តាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យពង្រីកអនុវិទ្យាល័យ " **ហ៊ុន សែន ពោធិ៍អំពិល** " បច្ចុប្បន្ន ទៅជាវិទ្យាល័យ " **ហ៊ុន សែន ពោធិ៍អំពិល** " ស្ថិតនៅក្នុង ឃុំ សំបូរ ស្រុក ទ្រាំង ខេត្ត តាកែវ ចាប់ពីឆ្នាំសិក្សា ២០០៥-២០០៦ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត តាកែវ នាយកវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី១៦ ខែ កញ្ញា ឆ្នាំ២០០៥

បណ្ឌិត គឹម សេង

កន្លែងទទួលៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តតាកែវ " ដើម្បីជាពត៌មាន"
- ដូចប្រការ៥
- កាលប្បវត្តិ-ឯកសារ នា.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ១៧១៧ អយក.ប្រក

ប្រកាស

ស្តីពីការបើកវិទ្យាល័យ " ទួលប្រាសាទ "

ស្ថិតនៅក្នុង ឃុំ ប៉ោយប៉ែត ស្រុក អូរជ្រៅ ខេត្ត បន្ទាយមានជ័យ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៩២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អ:ចទម ចុះថ្ងៃទី ០២ មេសា ១៩៩៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ចុះថ្ងៃទី ០៦ កក្កដា ២០០៥ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្ត បន្ទាយមានជ័យ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យបើកវិទ្យាល័យដែលមានឈ្មោះថា : វិទ្យាល័យ " **ទួលប្រាសាទ** " ស្ថិតនៅក្នុង ឃុំ ប៉ោយប៉ែត ស្រុក អូរជ្រៅ ខេត្ត បន្ទាយមានជ័យ ចាប់ពីឆ្នាំសិក្សា ២០០៥-២០០៦ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខ នៃវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត បន្ទាយមានជ័យ និងនាយកវិទ្យាល័យ សាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ ៧ ឆ្នាំ២០០៥

ហត្ថលេខា កុល ផេង

កន្លែងទទួល:

- ទីស្តីការគណ:រដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណ:
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តបន្ទាយមានជ័យ "ដើម្បីជាពត៌មាន"
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ នា.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: [illegible] អយក.ប្រក

ប្រកាស

ស្តីពីការពង្រីកអនុវិទ្យាល័យ " **វិហារសួគ៌** " ទៅជាវិទ្យាល័យ " **វិហារសួគ៌** "

ស្ថិតនៅក្នុង ឃុំ វិហារសួគ៌ ស្រុក ខ្សាច់កណ្តាល ខេត្ត កណ្តាល

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងពាក្យស្នើសុំរបស់សហគមន៍ ឃុំ វិហារសួគ៌ ស្រុក ខ្សាច់កណ្តាល ចុះថ្ងៃទី ២១ មេសា ២០០៥ ដោយមានការឯកភាពពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យពង្រីកអនុវិទ្យាល័យ " **វិហារសួគ៌** " បច្ចុប្បន្ន ទៅជាវិទ្យាល័យ " **វិហារសួគ៌** " ស្ថិតនៅក្នុង ឃុំ វិហារសួគ៌ ស្រុក ខ្សាច់កណ្តាល ខេត្ត កណ្តាល ចាប់ពីឆ្នាំសិក្សា ២០០៥-២០០៦ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រការនេះ ត្រូវទុកជានិរាករណ៍ ។

